សមាគមធនាគារនៅកម្ពុជា
THE ASSOCIATION OF BANKS IN CAMBODIA

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
Cambodia Microfinance Association

# អ្នកសារព័ត៌មាន៥រូប ជាប់ជ័យលាភី ក្នុងកម្មវិធីប្រកួតប្រជែងនិពន្ធអត្ថបទសារព័ត៌មាន របស់សមាគមធនាគារ និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា

ម្ចាស់ជ័យលាភីពានរង្វាន់៥រូប ដែលបានចូលរួមប្រកួតប្រជែងនិពន្ធអត្ថបទសារព័ត៌មានស្តីពី «ការចូលរួមចំណែករបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងការលើកស្ទួយជីវភាពប្រជាជនកម្ពុជា» ត្រូវបានប្រកាសឱ្យដឹងជាផ្លូវការ កាលពីថ្ងៃសុក្រទី៥ ខែសីហា នៅសណ្ឋាគារកាំបូឌីយ៉ាណា។

1) ម្ចាស់ជ័យលាភីលេខ ១ បានទៅ កញ្ញា អ៊ូ សុខមាន អ្នកសារព័ត៌មានមកពី សារព័ត៌មានថ្មីៗ ដែលផលិតអត្ថបទមានចំណងជើងថា៖«ធនាគារក្នុងទូរសព្ទដៃពលរដ្ឋខ្មែរប្រែក្លាយខ្លួនទៅជាពលរដ្ឋឌីជីថល» (https://thmeythmey.com/?page=detail&id=113564)
2) ជ័យលាភីលេខ២ បានដល់ កញ្ញា អ៊ីសា រ៉ហ៊ីណី អ្នកសារព័ត៌មានមកពី សារព័ត៌មានថ្មីៗដូចគ្នា ដែលផលិតអត្ថបទព័ត៌មានមានចំណងជើងថា៖« ការប្រើប្រាស់កម្ចីចំគោលដៅនាំឱ្យអាជីវកម្មរីកចម្រើននិងគេចផុតពីអន្ទាក់បំណុល» (https://thmeythmey.com/?page=detail&id=113551) ,
3) ជ័យលាភីលេខ៣ បានទៅលោក ស៊ុំ ម៉ាណេត អ្នកសារព័ត៌មាន មកពីសារព័ត៌មាន AMS Economy ដែលផលិតអត្ថបទព័ត៌មានមានចំណងជើងថា៖«កម្ចីឥណទានផ្លូវការជាប្រភពទុនដ៏សំខាន់សម្រាប់ការពង្រីកអាជីវកម្ម» https://economy.ams.com.kh/finance/news/official-loans-are-an-important-source-of-capital-for-business-expansion./
4) ម្ចាស់ជ័យលាភីលេខ៤ បានលើកញ្ញា សាន ស្រីនិច អ្នកសារព័ត៌មាន បណ្តាញសារព័ត៌មានអប្សរា (AMS) ដែលផលិតអត្ថបទព័ត៌មានមានចំណងជើងថា៖«ការប្រើប្រាស់ឥណទានឲ្យចំគោលដៅពិតជាធ្វើឲ្យអាជីវកម្មលូតលាស់ទៅតាមការគ្រោងទុក» (https://economy.ams.com.kh/finance/news/using-credit-on-purpose-really-makes-the-business-grow/)
5) ជ័យលាភីលេខ៥ បានលើ លោក មៅ សំណាង អ្នកសារព័ត៌មានមកពី បណ្តាញព័ត៌មានអប្សរា (AMS) ដែលផលិតអត្ថបទមានចំណងជើងថា៖« ១ម៉ឺនដុល្លារសម្រាប់អនាគតសុវត្ថិភាពស្បៀងអាហារ និងមុខរបរគ្រួសារខ្ញុំ»។

ពិធីប្រគល់ពានរង្វាន់ដល់អ្នកសារព័ត៌មាននេះ ធ្វើឡើងក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន, **ឯកឧត្តម រ័ត្ន សុវណ្ណរ:** ឧបការីទេសាភិបាល និងជាអគ្គនាយកត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា **លោក រ័ត្ន សោភ័ណ** អនុប្រធានសមាគមធនាគារនៅកម្ពុជា **លោក សុខ ខឿន** ប្រធានក្រុមប្រឹក្សាភិបាល សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា **លោក ប៉ែន មុណា** ប្រធានក្លិបអ្នកកាសែតកម្ពុជា និងឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និង

ឯកឧត្តម លោកជំទាវប្រតិភូអមក្រសួងព័ត៌មាន ធនាគារជាតិនៃកម្ពុជា ក្លិបអ្នកកាសែតកម្ពុជា សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា មិត្តៗអ្នកសារព័ត៌មាន និងភ្ញៀវជាតិ អន្តរជាតិ ប្រមាណជាង ១០០នាក់។

មានមតិស្វាគមន៍ក្នុងអង្គពិធី **លោក រ័ត្ន សោភ័ណ** អនុប្រធានសមាគមធនាគារនៅកម្ពុជា បានអបអរសាទរដល់ជ័យលាភីទាំង៥រូប។ លោកបានមានប្រសាសន៍ថា៖«អ្នកសារព័ត៌មានគឺជាដៃគូដែលមិនអាចខ្វះបាន ពីព្រោះតាមរយៈមាតិកាព័ត៌មានដែលផលិតឡើងដោយអ្នកសារព័ត៌មានជាច្រើនជុំវិញវិស័យហិរញ្ញវត្ថុ នឹងជាជំនួយស្មារតីដល់ប្រជាពលរដ្ឋ ក្នុងការយល់ដឹងពីសិទ្ធិក្នុងការប្រើប្រាស់ ជ្រើសរើស ចរចា និង ប្រាស្រ័យទាក់ទងទៅនឹងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ ។

លោក សោភ័ណ បានគូសបញ្ជាក់ទៀតថា៖«ជាមួយនឹងកម្មវិធីប្រឡងប្រជែងនិពន្ធអត្ថបទសារព័ត៌មានស្តីពី "**ការចូលរួមចំណែករបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងការលើកស្ទួយជីវភាពប្រជាជនកម្ពុជា** ដែលបានធ្វើឡើងនេះ វិស័យធនាគារនិងហិរញ្ញវត្ថុ និងវិស័យសារព័ត៌មាន នឹងបង្កើនកិច្ចសហប្រតិបត្តិការកាន់តែប្រសើរឡើងបន្ថែមទៀត ដើម្បីចូលរួមចំណែកផ្សព្វផ្សាយ បង្កើតមាតិកាព័ត៌មានឱ្យបានច្រើនអំពីតថភាព នៃវិស័យធនាគារ និងហិរញ្ញវត្ថុ ដើម្បីជាឧត្តមប្រយោជន៍ដល់សារធារណជន។ លើសពីនេះជាមួយនឹងវេទិកានាពេលនេះមិត្តៗអ្នកសារព័ត៌មានក៏អាចកសាងបណ្តាញបន្ថែមទៀតរវាងធនាគារិក និងអ្នកនៅក្នុងវិស័យផ្សេងៗទៀតផងដែរ។»

មានមតិបិទកម្មវិធីបណ្តុះបណ្តាលនិងពិធីប្រគល់ពានរង្វាន់ដល់អ្នកសារព័ត៌មាន **ឯកឧត្តម រ័ត្ន សុវណ្ណានុះ** ឧបការីទេសាភិបាល និងជាអគ្គនាយកត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា បានកោតសសើរចំពោះគំនិតផ្តួចផ្តើមរបស់ សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងក្លិបអ្នកកាសែតកម្ពុជា ដែលបានសហការរៀបចំវគ្គបណ្តុះបណ្តាលដល់អ្នកសារព័ត៌មាន និងកម្មវិធីប្រកួតប្រជែងពានរង្វាន់លើការនិពន្ធអត្ថបទសារព័ត៌មានស្តីពី ការចូលរួមចំណែករបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្នុងការការលើកស្ទួយជីវភាពប្រជាជនកម្ពុជា។ ឯកឧត្តមបានបន្តទៀតថា គំនិតផ្តួចផ្តើមនេះ នឹងជួយឱ្យអ្នកសារព័ត៌មានយល់ដឹងបន្ថែមទាក់ទងនឹងប្រព័ន្ធធនាគារនៅកម្ពុជា ដែលក្នុងនោះរួមមានមុខងារភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ច្បាប់ និងបទប្បញ្ញត្តិសំខាន់ៗ ព្រមទាំងវឌ្ឍនភាពនិងបញ្ហាប្រឈមរបស់ប្រព័ន្ធធនាគារ។

**ឯកឧត្តម អគ្គនាយកត្រួតពិនិត្យ** បានបញ្ជាក់យ៉ាងដូច្នេះថា៖«វត្តមានអ្នកសារព័ត៌មានទាំងអស់នាពេលនេះ ឆ្លុះបញ្ចាំងអំពីការចូលរួមផ្សព្វផ្សាយ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។ ធនាគារជាតិនៃកម្ពុជា សូមលើកទឹកចិត្តឱ្យអ្នកសារព័ត៌មានបន្តផ្សព្វផ្សាយព័ត៌មានហិរញ្ញវត្ថុ ដើម្បីចែករំលែក

ចំណេះដឹងដ៏សំខាន់នេះទៅសាធារណជន និងប្រជាជនដែលមិនទាន់បានយល់ដឹងអំពីការប្រើប្រាស់សេវាហិរញ្ញវត្ថុច្បាស់លាស់។»

យ៉ាងណាមិញ **លោក សុខ ឿន** ប្រធានក្រុមប្រឹក្សាភិបាល សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានអបអរសាទរដល់ជ័យលាភីទាំង៥រូប និងបានគូសបញ្ជាក់ថា សមាគមមីក្រូហិរញ្ញវត្ថុតែងតែបានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់តួនាទីរបស់អ្នកសារព័ត៌មានក្នុងការបំពេញការងារវិជ្ជាជីវៈរបស់ខ្លួន។ លោកបានបន្ថែមទៀតថា វាពិតជាមានសារៈសំខាន់ណាស់ដែលបងប្អូនអ្នកសារព័ត៌មានបានយល់ច្បាស់ និងស៊ីជម្រៅពីវិស័យធនាគារនិងហិរញ្ញវត្ថុ និងកិច្ចខិតខំប្រឹងប្រែងរបស់ភាគីទាំងអស់ ក្នុងការអភិវឌ្ឍវិស័យនេះឱ្យមានការរីកចម្រើនប្រកបដោយបរិយាបន្ន ការទទួលខុសត្រូវសង្គម និងការការពារអតិថិជន ហើយវិស័យនេះក៏បានចូលរួមចំណែកយ៉ាងសកម្មក្នុងកំណើនសេដ្ឋកិច្ចជាតិផងដែរ។ លោក សុខ ឿន ក៏បានលើកទឹកចិត្តដល់គ្រឹះស្ថានជាសមាជិកទាំងអស់ឱ្យចូលរួមធ្វើការងារកាន់តែជិតស្និទ្ធ ជាមួយប្រព័ន្ធផ្សព្វផ្សាយក្នុងការចែករំលែកព័ត៌មានដល់មិត្តអ្នកសារព័ត៌មានផងដែរ។

មានប្រសាសន៍អបអរសាទរ និងបិទកម្មវិធី **ឯកឧត្តម ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មានវាយតម្លៃខ្ពស់ចំពោះសមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងក្លឹបអ្នកកាសែតកម្ពុជា ដែលរៀបចំនូវវគ្គបណ្តុះបណ្តាលការយល់ដឹងពីវិស័យធនាគារ និងហិរញ្ញវត្ថុឡើង ហើយក៏មានការរៀបចំការប្រកួតប្រជែងពានរង្វាន់ស្តីពី «ការចូលរួមចំណែករបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងការលើកស្ទួយជីវភាពប្រជាជនកម្ពុជា» ផងដែរ។

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន បានលើកឡើងថា ការយល់ដឹងរបស់អ្នកសារព័ត៌មានអំពីវិស័យធនាគារ និងហិរញ្ញវត្ថុ គឺពិតជាមានសារសំខាន់ណាស់ ដើម្បីផ្តល់នូវព័ត៌មានច្បាស់លាស់ពីវិស័យធនាគារ និងហិរញ្ញវត្ថុជូនប្រជាជន ក្នុងការសម្រេចចិត្តជ្រើសរើស រកសេវាហិរញ្ញវត្ថុបានត្រឹមត្រូវ។ ឯកឧត្តមរដ្ឋមន្ត្រីបានចាត់ទុកវិស័យធនាគារ និងហិរញ្ញវត្ថុ ជាបេះដូងនៃសេដ្ឋកិច្ចរបស់ប្រទេសដូច្នេះដែរ កាលណាវិស័យធនាគារ និងហិរញ្ញវត្ថុរីកចម្រើន វិស័យសេដ្ឋកិច្ចក៏រីកចម្រើនដូចគ្នា។ ឯកឧត្តមរដ្ឋមន្ត្រីបញ្ជាក់យ៉ាងដូច្នេះថា៖ «ខ្ញុំសុំឲ្យសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុ សូមបន្តធ្វើយ៉ាងណាជំរុញអក្ខរកម្មធនាគារ ហិរញ្ញវត្ថុនេះចំពោះអ្នកសារព័ត៌មានឲ្យកាន់តែរីកចម្រើន ហើយចំពោះអ្នកសារព័ត៌មានយើងសំខាន់បំផុត មូលដ្ឋាននៃធនាគារ ហិរញ្ញវត្ថុ គឺទំនុកចិត្ត ត្រូវស្វែងរកប្រភពព័ត៌មាន ឲ្យបានច្បាស់លាស់ ដើម្បីធានាឲ្យមានស្ថិរភាពផ្នែកអារម្មណ៍ដល់ប្រជាជន ធ្វើឲ្យមានស្ថិរភាពផ្នែកហិរញ្ញវត្ថុ និងធនាគារ ក្នុងប្រទេសយើង»។

គួសបញ្ជាក់ដែរថា កម្មវិធីប្រឡងប្រជែងនិពន្ធអត្ថបទសារព័ត៌មានស្តីពី "**ការចូលរួមចំណែករបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងការលើកស្ទួយជីវភាពប្រជាជនកម្ពុជា** បានចូលរួមចំណែក ទី១/-លើកកម្ពស់ការយល់ដឹងពីវិស័យហិរញ្ញវត្ថុ និងបង្កើនកិច្ចសហប្រតិបត្តិការ កសាង/

បង្កើតប្រភពព័ត៌មានដែលគួរឱ្យទុកចិត្តរវាងវិស័យហិរញ្ញវត្ថុនិងអ្នកសារព័ត៌មាន, ទី២/- ចែករំលែកបទពិសោធន៍ផ្ទាល់របស់អ្នកជំនាញក្នុងការពង្រឹងការប្រាស្រ័យទាក់ទងគ្នាឱ្យមានប្រសិទ្ធភាពខ្ពស់រវាងវិស័យព័ត៌មាន និងវិស័យហិរញ្ញវត្ថុ និងទី៣/- កសាងបណ្តាញទំនាក់ទំនងបន្ថែមរវាង ធនាគារិក និងអ្នកសារព័ត៌មាន៕

**<u>សម្រាប់ព័ត៌មានបន្ថែម៖</u>**

១. លោក សុខ ចាន់ នាយកផ្នែកបរិយាបន្នហិរញ្ញវត្ថុ និងទំនាក់ទំនងសាធារណៈនៃសមាគមធនាគារនៅកម្ពុជា, លេខទំនាក់ទំនង៖ ០៩២ ៦៨ ៣៣៣០, អ៊ីម៉ែល៖ abc_fi@abc.org.kh

២. លោក កាំង តុងងី ប្រធាននាយកដ្ឋានទំនាក់ទំនង នៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា, លេខទំនាក់ទំនង៖ ០៩៥ ២៦២ ១១១, អ៊ីម៉ែល៖ hcp@cma-network.org

សមាគមធនាគារនៅកម្ពុជា
THE ASSOCIATION OF BANKS IN CAMBODIA

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
Cambodia Microfinance Association

# Five Journalists awarded in a News Writing Competition: ABC and CMA

Five journalists were crowned champions in the News Writing Competition on "**The Contribution of Banking and Financial Sector to the Cambodian Livelihoods.”** The official announcement of the winners took place on Friday, August 5 at the Hotel Cambodiana, Phnom Penh.

The first place was awarded to Ou Sokmean, a journalist at Thmey Thmey (https://thmey thmey.com /?page=detail&id=113564); while the second roundup was awarded to Isa Rohyny, a journalist at Thmey Thmey (https://thmeythmey.com/?page=detail&id=113551); the third place was to Sum Manet, a journalist at AMS Economy; the fourth winner was San Sreynich, a journalist at Apsara Media Service (AMS) https://economy.ams.com.kh/finance/news/using-credit-on-purpose-really-makes-the-business-grow/; the fifth winner went to Mao Samnang, a journalist at AMS https://economy.ams.com.kh/finance/news/using-credit-on-purpose-really-makes-the-business-grow/).

The award ceremony was presided over by His Excellency Khieu Kanharith, Minister of Information, H.E Rath Sovannorak, Assistant Governor and Director-General of Banking Supervision, the National Bank of Cambodia, Mr. Rath Sophoan, Vice-Chairman of the Association of Banks in Cambodia, Mr. Sok Voeun, Chairman of the Cambodia Microfinance Association, Mr. Pen Bonna, President of the Club of Cambodian Journalists and His Excellency Lok Chumteav, Secretary of State, Undersecretary of State and His Excellency Lok Chumteav, Delegation of the Ministry of Information, National Bank of Cambodia, Club of Cambodian Journalists, Association of Banks in Cambodia, Cambodia Microfinance Association, local and international Journalists. In total, around 100 participants were present at the event.

**During the welcoming remarks, Mr. Rath Sophoan, Vice-Chairman of the Association of Banks in Cambodia**, congratulated the five winners. He said: "Journalists are an indispensable partner because the news content produced by journalists related to Banking and Finance would help people to understand the right to choose, negotiate and how to make the right decisions to use financial services and products.

Mr. Sophoan emphasized, "With the news writing competition program on "The Contribution of Banking and Financial Sector to the Cambodian Livelihoods”, the banking and financial sector and the media would further enhance cooperation in order to contribute to the dissemination of news content about the realities of the banking and financial sector for the benefit of the public. In addition, with this forum, journalists can also build more networks between bankers and people in other related fields.

**Delivered closing remarks at the Media Award Handover Ceremony for Journalists, H.E Rath Sovannarak, Assistant Governor and Director-General of Banking Supervision**, the National Bank of Cambodia, hailed the initiatives of the two Associations and the Club of Cambodian Journalists, which co-organized a training course for journalists and conducted the news writing competition on the "The Contribution of Banking and Financial Sector to the Cambodian Livelihoods”. He added that this initiative would help journalists to have a better understanding of the banking system in Cambodia, including the functions and duties of the National Bank of Cambodia, Banking and Financial Institutions Operations, laws and regulations, as well as progress and challenges of the banking system in the Kingdom.

“The presence of all journalists at this time reflects the participation in promoting and improving the financial inclusion in Cambodia,” he said. The National Bank of Cambodia encourages journalists to continue to disseminate the banking and financial news to share this important knowledge with the public and people, who do not yet clearly understand the use of financial services and products.

**Mr. Sok Voeun, Chairman of the Cambodia Microfinance Association**, congratulated the five winners and emphasized that the Association has always been actively involved in promoting the role of journalists in their profession. He noted that it is important for journalists to have a clear and in-depth understanding of the banking and financial sector and the efforts of all parties to develop the sector in an inclusive, consumer protective, and responsible manner. The sector has actively contributed to national economic growth. Mr. Sok Voeun also encouraged all member institutions to work more closely with the media to share information with fellow journalists.

**H.E Khieu Kanharith, Minister of Information**, highly appreciated the Association of Banks in Cambodia, the Cambodia Microfinance Association, and the Club of Cambodian Journalists for organizing a training course on banking and finance and conducting the news writing competition on "The Contribution of Banking and Financial Sector to the Cambodian Livelihoods.” The Minister of Information stated that acquired knowledge of the Banking and Financial sector is important for journalists so as to them being able to deliver accurate information to the public in order to help them making the right decision when it comes to the use of financial services and products.

H.E Kanharith considered that the banking and financial sector is the heart of the country's economy, so as the banking and finance sector grows, so does the economic sector. "I would like to call on the Association of Banks in Cambodia and the Cambodia Microfinance Association to continue to promote Banking Literacy to the journalists,” adding that to our journalists, the most important basis of the Banking and Financial sector is "Trust”. They shall seek trusted sources in the Banking and Financial sector to ensure that people have peace of mind and trust when they consume the news.”

The news writing competition program on "The Contribution of Banking and Financial Sector to the Cambodian Livelihoods,” was initiated; first, to raise awareness of the financial sector and increase cooperation to build a network and establish a trusted source and reliable information between the financial sector and the media. The second is to share personal experiences of experts to strengthen effective communication between the Media and the financial sector, and the third is to build an additional network between bankers and journalists.

## For More Information:

1. Mr. Sok Chan, Head of Financial Inclusion and Public Relations of The Association of Banks in Cambodia, Tel: 092 68 3330, Email: abc_fi@abc.org.kh

2. Mr. Kaing Tongngy, Head of Communication Department of Cambodia Microfinance Association, Tel: 095 262 111, email: hcp@cma-network.org